## នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
## នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 04-Nov-2011, 15:30
CMS/CFO: Uch Arun

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## សំណើរបស់សហព្រះរាជអាជ្ញា
## សុំឲ្យបញ្ជាក់ពីវិសាលភាពនៃសវនាការដំបូង

---

**អ្នកដាក់ឯកសារ:**

សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

អង្គជំនុំជម្រះសាលាដំបូង:
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រមJean-Marc LAVERGNE
ចៅក្រម យូ ឧត្តរា

សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ចម្លងជូន:**

ជនជាប់ចោទ:
នួន ជា
អៀង សារី
អៀង ធីរិទ្ធ
ខៀវ សំផន

មេធាវីការពារក្ដីជនជាប់ចោទ:
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe
លោក អាង ឧត្ដម
លោក Michael G.KARNAVAS

លោក ផាត់ ពៅស៊ាង
កញ្ញា Diana ELLIS QC
លោក សរ ស្វូវ៉ាន
លោក Jacques VERGÈS

# I. សំណើ

១. អង្គជំនុំជម្រះសាលាដំបូង ថ្មីៗនេះបានធ្វើគោលគម្រោងស្តីពីវិសាលភាពនៃសវនាការដំបូង នៅក្នុងសំណុំរឿងលេខ០០២ តាមរយៈដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់ខ្លួន ដោយអនុលោមតាមវិធាន៨៩ស្ទួនពីរ នៃវិធានផ្ទៃក្នុង ("ដីកាបំបែកដំណើរការនីតិវិធី")[1] ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១, សេចក្តីសម្រេចរបស់ខ្លួនទៅលើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យពិចារណាឡើងវិញ អំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង ("សេចក្តីសម្រេចបំបែកដំណើរការនីតិវិធី")[2] និងដីកាកំណត់កាលបរិច្ឆេទនៃការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ និងសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ ("ដីកាកំណត់កាលបរិច្ឆេទ")[3] ។ ដូចមានហេតុផលនានារៀបរាប់នៅខាងក្រោមនេះ សហព្រះរាជអាជ្ញាសូមស្នើឱ្យ អង្គជំនុំជម្រះ សាលាដំបូងធ្វើការបញ្ជាក់ពីវិសាលភាពនៃសវនាការដំបូង និងបន្ទាប់មកទៀត វិសាលភាពនៃការអនុញ្ញាតឱ្យធ្វើការសាកសួរ និងការទទួលយកភស្តុតាង ។

២. ពាក់ព័ន្ធទៅនឹងវិសាលភាពជាសក្តានុពលនៃសវនាការដំបូង កថាខណ្ឌទី៥, ៦ និង ៧ នៃដីកាបំបែកដំណើរការនីតិវិធី និង កថាខណ្ឌទី១២ នៃ សេចក្តីសម្រេចបំបែកដំណើរការនីតិវិធី បានសរសេរដូចតទៅនេះ៖

> *៥. អង្គជំនុំជម្រះសាលាដំបូង បានសម្រេចបំបែកកិច្ចដំណើរការនីតិវិធីដើម្បីជាប្រយោជន៍នៃយុត្តិធម៌។ បន្ថែមពីលើចំណុចនានាដូចបានរៀបរាប់នៅក្នុងកថាខណ្ឌទី ១ ខាងលើ ការជំនុំជម្រះដំណាក់កាលដំបូង លើសំណុំរឿង ០០២ នេះ រួមមាន៖*
>
> *ក) ការចោទប្រកាន់លើអង្គហេតុ ដែលបានរៀបរាប់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជន នៅក្នុងដំណាក់កាលទី១ និងដំណាក់កាលទី២។*
>
> *ខ) ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ រួមមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញ (លើកលែងដោយហេតុផលសាសនា) ការជន្លៀស*

---

[1] **E124** ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន៨៩ស្ទួនពីរ នៃវិធានផ្ទៃ, ថ្ងៃទី២២ កញ្ញា ២០១១, ("ដីកាបំបែកដំណើរការនីតិវិធី")។

[2] **E124/7** សេចក្តីសម្រេចរបស់ខ្លួនទៅលើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យពិចារណាឡើងវិញ អំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ **E124/7**) និងសំណើសុំពាក់ព័ន្ធនានា ព្រមទាំងឧបសម្ព័ន្ធ, ថ្ងៃទី១៨ តុលា ២០១១, ("សេចក្តីសម្រេចបំបែកដំណើរការនីតិវិធី") ។

[3] **E131** ដីកាកំណត់កាលបរិច្ឆេទនៃការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ និងសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២, ថ្ងៃទី១៨ តុលា ២០១១ ។

*ដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ (ដោយហេតុថា អង្គហេតុទាំងនេះពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជន នៅក្នុងដំណាក់កាលទី១ និងដំណាក់កាលទី២)។*

*៦. នៅក្នុងដំណាក់កាលណាមួយក៏បាន អង្គជំនុំជម្រះសាលាដំបូងអាចសម្រេចដាក់បញ្ចូលបន្ថែមនូវផ្នែកផ្សេងៗទៀតនៃដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០២ ប្រសិនបើសិទ្ធិដែលត្រូវទទួលបានការការពារខ្លួន ត្រូវបានផ្តល់ជូននូវឱកាសក្នុងការរៀបចំការការពារបានប្រកបដោយប្រសិទ្ធិភាព ហើយនិងភាគីនានាត្រូវបានជូនដំណឹងក្នុងរយៈពេលសមស្រប។ នៅពេលបញ្ចប់ការជំនុំជម្រះលើកដំបូងនេះ អង្គជំនុំជម្រះនឹងចេញសាលក្រមពាក់ព័ន្ធនឹងការចោទប្រកាន់ទាំងនេះដោយផ្តន្ទាទោសសមស្រប ប្រសិនបើរកឃើញថាមានពិរុទ្ធភាព។*

*៧. អង្គហេតុពាក់ព័ន្ធនឹងសហករណ៍ ការដ្ឋាន មន្ទីរសន្តិសុខ កន្លែងសម្លាប់មនុស្ស ឬអង្គហេតុពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជននៅក្នុងដំណាក់កាលទី ៣ នឹងមិនត្រូវបានលើកយកមកដេញដោលនៅក្នុងការជំនុំជម្រះលើកដំបូងនេះទេ។ លើសពីនេះទៀត បទចោទប្រកាន់ទាំងអស់ ដូចជា បទប្រល័យពូជសាសន៍ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ត្រូវទុកដើម្បីលើកយកទៅដេញដោលនៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីក្រោយៗទៀតនៅក្នុងសំណុំរឿង ០០២[4]។*

*១២. នៅក្នុងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងមិនបានបដិសេធចោលនូវលទ្ធភាពនៃការដាក់បញ្ចូលការចោទប្រកាន់ ឬបទចោទបន្ថែមនៅក្នុងការជំនុំជម្រះដំណាក់កាលដំបូងក្នុងសំណុំរឿង ០០២ ឡើយ នៅពេលដែលកាលៈទេសៈអនុញ្ញាត។ ទោះបីជាអង្គជំនុំជម្រះកត់សម្គាល់នូវការចង្អុលបង្ហាញរបស់សហព្រះរាជអាជ្ញានៅក្នុងសំណើសុំ របស់ខ្លួនអំពីបញ្ហាបន្ថែមដែលអាចមាន សម្រាប់ដាក់បញ្ចូលនៅក្នុងការជំនុំជម្រះដំណាក់កាលដំបូង ហើយអង្គជំនុំជម្រះត្រូវបានណែនាំដោយការយល់ឃើញរបស់សហព្រះរាជអាជ្ញាថា ជាការចោទប្រកាន់ជាអាទិភាពសម្រាប់ធ្វើការពិចារណាក្នុងអំឡុងដំណាក់កាលនៃការជំនុំជម្រះក្រោយៗទៀតក៏ដោយ ក៏អង្គជំនុំជម្រះយល់ឃើញថា ពុំមានមូលដ្ឋានក្នុងការពិចារណាឡើងវិញលើដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់ខ្លួននៅដំណាក់កាលនេះឡើយ* [កំណត់សម្គាល់ជើងទំព័រត្រូវបានលុបចោល] ។

៣. ដើម្បីធានាថា កុំឲ្យសហព្រះរាជអាជ្ញា និងភាគីនានាមានការភាន់ច្រឡំទាក់ទងទៅនឹងវិសាលភាពនៃសវនាការដំបូង សហព្រះរាជអាជ្ញា សូមស្នើឲ្យ អង្គជំនុំជម្រះសាលាដំបូងធ្វើការបញ្ជាក់ថា

---

[4] ដីកាបំបែកដំណើរការនីតិវិធី, កំណត់សម្គាល់ខាងលើ លេខ១, ត្រង់កថាខណ្ឌទី ៥-៧ ។

កថាខណ្ឌទី៧ នៃដីកាបំបែកដំណើរការនីតិវិធី តាមវិធីណាមួយក៏ដោយ មិនកម្រិតឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានយោងនៅក្នុងកថាខណ្ឌទី៦ ក្នុងការដាក់បញ្ចូលនូវការចោទប្រកាន់ ឬបទចោទនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជាការបន្ថែមទៅនឹងការចោទប្រកាន់ ឬ បទចោទដែលបានកំណត់អត្តសញ្ញាណរួចហើយនៅក្នុងកថាខណ្ឌទី៥ នៃដីកាបំបែកដំណើរការនីតិវិធី នៅក្នុងសវនាការដំបូង នោះឡើយ[5] ។

៤. ចំពោះវិសាលភាពនៃការចោទសួរដេញដោលដែលអាចអនុញ្ញាតឲ្យបានអំពីគោលនយោបាយចំនួនប្រាំដែលបង្កើតជាសហកម្មឧក្រិដ្ឋកម្មរួម និងអំពីតួនាទីនិងការចូលរួមរបស់ជនជាប់ចោទនៅក្នុងគោលនយោបាយទាំងប្រាំនេះ សហព្រះរាជអាជ្ញា សូមស្នើឲ្យធ្វើការបំភ្លឺបន្ថែមទៀត។ សេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីមានខ្លឹមសារដូចខាងក្រោមនេះ៖

> *១១. ដែលបន្តទៀតថា អង្គជំនុំជម្រះសាលាដំបូង នៅក្នុងផ្នែកដំបូងៗគេនៃសវនាការ និងផ្តោតការយកចិត្តទុកដាក់ទៅលើ**តួនាទីនិងការទទួលខុសត្រូវ** របស់ជនជាប់ចោទទាក់ទងទៅនឹង**រាល់គោលនយោបាយទាំងអស់ដែលពាក់ព័ន្ធនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះទាំងមូល** ក៏ប៉ុន្តែនឹងផ្តល់នូវសេចក្តីលំអិតនៃការពិចារណាអំពីអង្គហេតុនៅក្នុងសវនាការលើកដំបូង ជាសំខាន់ទៅលើចំណុចពិសេសនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានផលប៉ះពាល់ជាក់ស្តែងទៅដល់ជនរងគ្រោះគ្រប់គ្នាទាំងអស់នសរបបកម្ពុជាប្រជាធិបតេយ្យ(គឺបានន័យថាការផ្លាស់ទីលំនៅរបស់ប្រជាជននៅក្នុងដំណាក់កាលទីមួយនិងទីពីរ)[6] ។*

៥. ឧបសម្ព័ន្ធដែលភ្ជាប់ជាមួយនឹងដីកាសំរេចនេះ "រាយជាបញ្ជីអំពីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងទៅនឹងសវនាការជំនុំជម្រះក្តីលើកដំបូងលើសំណុំរឿងលេខ ០០២" នៅក្នុងកថាខណ្ឌទី១ ដែលមានចំណងជើងថា "ការរកឃើញនានាខាងអង្គហេតុ" ដែលនៅក្នុងអនុកថាខណ្ឌទី(vi) និងទី(vii) ដែលមានខ្លឹមសារថា៖

> ***(vi)*** *រកឃើញនានាខាងអង្គហេតុទាក់ទងនឹងសហកមកមឧក្រិដ្ឋកម្មរួម(១៥៦-១៥៩)។ និង*
>
> ***(vii)*** *គោលនយោបាយដូចដែលបានអនុវត្ត(១៦០-១៦៥) (ទាំងអស់គឺកំរិតត្រឹមតែការផ្លាស់ទៅលំនៅរបស់ប្រជាជនដែលនៅក្នុងដំណាក់កាលទីមួយ និងទីពីរប៉ុណ្ណោះ)។*

---

[5] សេចក្តីសម្រេចលើសំណើរបស់ កសព, កំណត់សម្គាល់ខាងលើ លេខ២, កថាខណ្ឌទី ១២ ។

[6] សេចក្តីសំរេចលើសំណើរបស់ កសព កំណត់សំគាល់ទី២ *ខាងដើម* កថាខណ្ឌទី១០។

៦. លើសពីនេះ នៅក្នុងឧបសម្ព័ន្ធដដែលនេះ នៅបន្ទាត់ចុងក្រោយបង្អស់នៃកថាខណ្ឌទី៣ដែលមានចំណងជើងថា "តួនាទីរបស់ជនជាប់ចោទ" ដែលជាប់ទាក់ទងទៅនឹងជនជាប់ចោទ មានខ្លឹមសារដូចខាងក្រោមនេះ[7]៖

> ការចូលរួមនៅក្នុងគោលបំណងរួម ***(គឺកំរិតត្រឹមតែការផ្លាស់ទីលំនៅរបស់ប្រជាជន*** *ដែលនៅក្នុងដំណាក់កាលទីមួយ និងទីពីរប៉ុណ្ណោះ)*។

៧. ការបំភ្លឺមួយចំនួនត្រូវបានផ្តល់ ក្នុងនាមជាវិសាលភាពដែលអាចអនុញ្ញាតឱ្យបាននៃការសួរដេញដោលតាមការទាញហេតុផលដែលបានធ្វើកាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ នៅក្នុងដីកាសំរេចស្តីពីការកំណត់កាលបរិច្ឆេទនៃការបើកសវនាការរបស់អង្គជំនុំជម្រះសាលាដំបូង ដែលនៅក្នុងនោះបានសំរេចថា៖

> ...នៅពេលដែលដីកាសំរេចស្តីការបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះ ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០១១ (ឯកសារលេខE124) ដែលបំបែកកិច្ចដំណើរការនីតិវិធីដាច់ដោយឡែកពីគ្នាឱ្យទៅជាការសវនាការជំនុំជម្រះក្តីតូចៗជាងនេះ ***ត្រូវបានគេគិតទុកថាសវនាការលើកដំបូងនេះនឹងផ្តល់នូវមូលដ្ឋានគ្រឹះទូទៅមួយសំរាប់គ្រប់វាលបទចោទប្រកាន់ទាំងអស់*** *ដែលរួមទាំងបទចោទនានាដែលនឹងត្រូវសួរដេញដោលនៅពេលនៅពេលក្នុងសវនាការក្រោយៗទៀតផង*[8] ។

៨. សូមស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងបញ្ជាក់ថា៖ (១) គោលនយោបាយទាំងប្រាំនេះ ដែលបង្កើតបានជាគោលបំណងរួមនៃសហកម្មឧក្រិដ្ឋកម្មរួមហើយនិងតួនាទី និងការចូលរួមរបស់ជនជាប់ចោទនៅក្នុងគោលនយោបាយទាំងនេះគឺជាបញ្ហាជាក់ស្តែងនៅក្នុងសវនាការលើកដំបូង។ និង (២) ហើយថាបញ្ហាទាំងនេះ ដែលតម្រូវឱ្យមានការសួរដេញដោល ដែលជាសក្ខីភាពដែលសំដៅផ្តោះទៅរកកំរិតដែលតម្រូវឱ្យមាន ដែលអាស្រ័យហេតុនេះ ត្រូវមានការសួរដេញដោល និងការទទួលយកនូវភស្តុតាងជាឯកសារ។ សូមគោរពជូនជាសេចក្តីសន្និដ្ឋានថា ការកំណត់សំរេចជាស្ថាពរជាមុនមួយអំពីការធ្វើសវការលើបញ្ហាទាំងពីរនេះគឺជាការចាំបាច់ណាស់ ប្រយោជន៍ដើម្បីសំរេចឱ្យបាននូវគោលដៅនានារបស់អង្គជំនុំជម្រះសាលាដំបូងដែលទាក់ទងទៅនឹងដីកាសំរេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី ជាពិសេស និងដើម្បីសំរេចឱ្យបាននូវវិធីសាស្ត្រនានាជាច្រើននៃការធ្វើសវនាការទៅលើការចោទប្រកាន់លើជនជាប់ចោទទាំងនេះ ជាទូទៅ។

---

[7] ឯកសារលេខ E124/7.1, ឧបសម្ព័ន្ធ: បញ្ជីរាយអំពីថាខណ្ឌ និងផ្នែកនានានៃសដីកាដំណោះស្រាយដែលទាក់ទងនឹងសវនាការជំនុំជម្រះក្តីលើកដំបូងនៅក្នុងសំណុំរឿងលេខ ០០២, ចុះថ្ងៃទី១៨ តុលា២០១១, ត្រង់ទំព័រទី១ ។

[8] **E131** ដីកាកំណត់កាលបរិច្ឆេទនៃការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ និងសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២, ថ្ងៃទី១៨ តុលា ២០១១ (សង្កត់ន័យបន្ថែមដោយ ***អក្សរដិតក្រាស់***) ។

៩. ដោយផ្អែកលើមូលដ្ឋាននៃអត្ថបទនៃសេចក្តីសំរេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី និងដីកាសំរេចស្តីពីការកំណត់កាលបរិច្ឆេទសំរាប់ការបើកសវនាការ គឺហាក់ដូចជាថាអង្គជំនុំជម្រះសាលាដំបូងមានបំណងចង់ឲ្យគោលនយោបាយទាំងប្រាំ និងការចូលរួមរបស់ជនជាប់ចោទនៅក្នុងគោលនយោបាយទាំងនេះក្លាយទៅជាបញ្ហាជាក់ស្តែងនៅក្នុងសវនាការជំនុំជម្រះក្តីលើកដំបូង ដែលតម្រូវឲ្យមានភស្តុតាង។ ក៏ប៉ុន្តែមកដល់ត្រង់ចំណុចនេះ គឺវាច្បាស់ណាស់ថាអង្គជំនុំជម្រះសាលាដំបូងមិនបានសំរេចអំពីថា ប្រសិនបើមានការចោទប្រកាន់ ឬបទចោទនានាបន្ថែមទៀតនោះ គឺនឹងត្រូវដាក់បញ្ចូលនៅក្នុងសវនាការលើកដំបូងបន្ថែមពីលើការរកឃើញនានាអំពីឧក្រិដ្ឋកម្មផ្សេងទៀត ក្រៅពីការផ្លាស់ទីលំនៅរបស់ប្រជាជននៅក្នុងដំណាក់កាលទីមួយនិងដំណាក់កាលទីពីរ ដែលទាក់ទងទៅនឹងឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានផ្តល់អត្តសញ្ញាណនៅក្នុងកថាខណ្ឌទី៦នៃដីកាសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី។

១០. ច្បាស់ណាស់ថា ជាការសំខាន់ដែលគោលនយោបាយទាំងប្រាំនៃសហកម្មឧក្រិដ្ឋកម្មរួម និងតួនាទីនិងការចូលរួមប្រព្រឹត្តិរបស់ជនជាប់ចោទនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួមនេះ ត្រូវបានពិនិត្យឲ្យបានជិតដល់នៅក្នុងដំណាក់កាលដំបូងនៃសវនាការដំបូងនេះដើម្បីអនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូងរក្សានូវមតិរបស់ខ្លួនក្នុងការបញ្ចូលបទចោទបន្ថែម ។ ការខកខានមិនបានធ្វើដូច្នេះ នឹងមានន័យថាប្រសិនបើអង្គជំនុំជម្រះសាលាដំបូង បញ្ចូលបទចោទបន្ថែមនៅពេលណាមួយនាពេលក្រោយមកក្នុងពេលសវនាការនេះ ភស្តុតាងដែលមានក្នុងដំណាក់កាលដំបូងនៃសវនាការទំនងជាមិនគ្រប់គ្រាន់សម្រាប់ការភ្ជាប់ជនជាប់ចោទទៅនឹងអង្គហេតុដែលបានអះអាងចោទប្រកាន់ ចំពោះបទចោទទាំងនោះទេ ។ ដោយហេតុថា វាជាគោលនយោបាយដែលជាប់ទាក់ទងនឹងអង្គហេតុចោទប្រកាន់ទាំងនោះ និងតួនាទីនិងការចូលរួមប្រព្រឹត្តរបស់ជនជាប់ចោទនៅក្នុងគោលនយោបាយទាំងនោះ ដូច្នេះនេះគឺជាការផ្តល់នូវការភ្ជាប់នេះ ។

១១. សហព្រះរាជអាជ្ញាបានកត់សម្គាល់បន្ថែមទៀតថា មានសាក្សីជាច្រើនដែលគេអាចកោះហៅដើម្បីផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងគោលនយោបាយទាំងប្រាំ មានការដឹងឮពីការអនុវត្តនូវគោលនយោបាយទាំងនោះទាក់ទងទៅនឹងការចោទប្រកាន់ ឬបទចោទផ្សេងៗទៀត (ជាឧទាហរណ៍ ទាក់ទងទៅនឹងមន្ទីរសន្តិសុខ ការដ្ឋាន និង សហករណ៍នានា) ដែលបច្ចុប្បន្នេះស្ថិតនៅក្រៅពីវិសាលភាពនៃសវនាការដំណាក់កាលដំបូង ដោយយោងទៅតាមដីកាបំបែកដំណើរការនីតិវិធី ។ សហព្រះរាជអាជ្ញា សូមស្នើសុំឲ្យមានការបញ្ជាក់ពីអង្គជំនុំជម្រះសាលាដំបូងថា តើសហព្រះរាជអាជ្ញាអាចសួរសំណួរដល់សាក្សីទាំងនេះអំពីអង្គហេតុទាំងអស់ដែលពួកគាត់បានដឹងឮទាក់ទងទៅនឹងការលើកឡើងចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយបានដែរឬទេ ។ ការណ៍នេះនឹងការពារកុំឲ្យចាំបាច់កោះហៅសាក្សីទាំងនេះជាថ្មីម្តងទៀត បើមានការបន្ថែមការចោទប្រកាន់ ឬបទចោទនានានៅពេលក្រោយណាមួយនៃសវនាការនេះ ឬជាសក្តានុពលនៅក្នុងសវនាការលើកក្រោយៗ ។

១២. ដើម្បីថែរក្សាគោលដៅរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការធានាចំពោះសវនាការប្រកបដោយប្រសិទ្ធិភាពជាបន្តបន្ទាប់នាពេលក្រោយមក ជាពិសេសគោលដៅក្នុង *"ការផ្តល់ឲ្យមាននូវមូលដ្ឋានគ្រឹះជាទូទៅមួយចំពោះគ្រប់បទចោទទាំងអស់ រួមទាំង បទចោទដែលនឹងត្រូវដេញដោលនៅក្នុងសវនាការនាពេលក្រោយមក"*[9] ការដាក់បញ្ចូលនូវការសួរដេញដោលចំពោះគោលនយោបាយ ទាំងប្រាំនេះ និងការចូលរួមប្រព្រឹត្តរបស់ជនជាប់ចោទ នៅក្នុងគោលនយោបាយនេះ គឺជាការចាំបាច់ ។ គ្មានមូលដ្ឋានគ្រឹះណាដែលមានប្រសិទ្ធិភាព និងជាក់ស្តែងដូច្នេះអាចនឹងមានសម្រាប់សវនាការនាពេលក្រោមមកឡើយ ប្រសិនបើគេគ្មានការដេញដោលឲ្យបានពេញលេញអំពីបញ្ហាទាំងនេះនៅក្នុងសវនាការបូងនេះ ។

១៣. ហេតុដូច្នេះ សូមស្នើថា បើមានភាពមិនស៊ីសង្វាក់ជាមួយគ្នានឹងអត្ថបទនេះនៃតាមសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធី និងដីកាសម្រេចរៀបចំសវនាការ និងអត្ថបទនៃឧបសម្ព័ន្ធភ្ជាប់នឹងសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនោះ ត្រូវតែដោះស្រាយយកតាមសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធី និងដីកាសម្រេចរៀបចំសវនាការ ។ ប៉ុន្តែ បើសិនជាអង្គជំនុំជម្រះសាលាដំបូងគ្មានបំណងសួរដេញដោលពីគោលនយោបាយទាំងប្រាំនេះទេ ក្រៅពីការជម្លៀសដោយបង្ខំ និងតួនាទីនិងការចូលរួមប្រព្រឹត្តរបស់ជនជាប់ចោទនៅក្នុងគោលនយោបាយទាំងនេះ សហព្រះរាជអាជ្ញាសូមស្នើឲ្យស្តាប់សវនាការសាក្សីចំនួន៦៥រូបដែលអង្គជំនុំជម្រះសាលា មានបំណងកោះហៅមកបំភ្លឺក្នុងដំណាក់កាលដំបូងនៃសវនាការដំបូងនេះ ដើម្បីគេអាចដាក់សេចក្តីសន្និដ្ឋានពាក់ព័ន្ធនឹងតម្លៃភស្តុតាងរបស់វា សម្រាប់ការបញ្ជាក់អំពីបញ្ហាជាក់ស្តែងក្នុងសវនាការដំបូង ។ សំណើនេះត្រូវបានធ្វើឡើងក្នុងគោលបំណងដើម្បីជួយអង្គជំនុំជម្រះសាលាដំបូងក្នុងការធានាថា សវនាការដំបូងមានទាំងភាពត្រឹមត្រូវយុត្តិធម៌ផង និងប្រព្រឹត្តទៅបានឆាប់រហ័សផង ។

## II. សំណងជួសជុលដែលស្នើឡើង

១៤. អាស្រ័យមូលហេតុដូចដូចបានលើកឡើងខាងលើនេះ សហព្រះរាជអាជ្ញាសូមស្នើដល់អង្គជំនុំជម្រះសាលាដំបូង៖

(ក) បញ្ជាក់ថា កថាខ័ណ្ឌទី៧ នៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី មិនត្រូវបានកម្រិតដោយកថាខ័ណ្ឌទី៧ ទោះក្នុងករណីណាក៏ដោយ និងថាអាស្រ័យហេតុដូច្នេះ ជនជាប់ចោទ និងភាគីនានាត្រូវបានជូនដំណឹងថា បទចោទណាមួយដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវបានធ្វើសវនាការនៅក្នុងសវនាការដំបូង ។

---

[9] *ក្នុងឯកសារដដែលដូចខាងលើ ។*

(ខ) បញ្ជាក់ថា គោលនយោបាយទាំងប្រាំនៃសហកម្មឧក្រិដ្ឋកម្មរួមដូចបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងតួនាទី និងការចូលរួមប្រព្រឹត្តរបស់ជនជាប់ចោទនៅក្នុងគោលនយោបាយទាំងនេះ គឺជាអង្គហេតុជាក់ស្តែងពិតប្រាកដទាំងអស់ដែលតម្រូវឲ្យមានការបញ្ជាក់នៅក្នុងសវនាការដំបូង ។

(គ) បំភ្លឺថាតើសាក្សីនានាអាចនឹងត្រូវបានសួរដេញដោលអំពីការអនុវត្តន៍គោលនយោបាយទាំងប្រាំនេះដែរឬទេ ទាក់ទងនឹងបទចោទផ្សេងទៀតដែលមាននៅក្នុងដីកាដំណោះស្រាយដែលមិនបាននគ្របដណ្តប់នៅក្នុងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនាពេលនេះ ។ និង

(ឃ) បើសិនអង្គជំនុំជម្រះសម្រេច មិនបញ្ចូលគោលនយោបាយនៃសហកម្មឧក្រិដ្ឋកម្មរួមទាំងប្រាំ និងតួនាទីរបស់ជនជាប់ចោទនៅក្នុងគោលនយោបាយទាំងនេះទេ សូមឲ្យអញ្ជើញសហព្រះរាជអាជ្ញា និងភាគីនានាឲ្យធ្វើសេចក្តីសន្និដ្ឋានជាបន្ទាន់ អំពីបញ្ជីសាក្សីដែលមានស្រាប់សម្រាប់ដំណាក់កាលដំបូងនៃសវនាការ ។

១៥. សហព្រះរាជអាជ្ញាសន្និដ្ឋានថា ការបញ្ជាក់បំភ្លឺដូចនេះ ពេលនេះនឹងបញ្ចៀសបាននូវការពន្យារពេលសវនាការលើអង្គសេចក្តី និងធានាថាការរៀបចំសវនាការរបស់ភាគីនានាកាន់តែជ្រាបច្បាស់ថែមទៀត ហេតុដូច្នេះរួមចំណែកធ្វើឲ្យសវនាការមួយកាន់តែមានប្រសិទ្ធិភាព និងកាន់តែឆាប់រហ័ស ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១១ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | [signature] |